NATIONAL BOWELCANCER SCREENING PROGRAM

Australian Government

<Date> លេខអត្តសញ្ញាណ <Consumer ID>

<Aust Post ID>
<Participant Given Name> <Participant Family Name>
<Preferred mailing address>
<Preferred mailing address>
<LOCALITY> <STATE> <POSTCODE>

ជូនចំពោះ <Participant Given Name> <Participant Family Name> ជាទីរាប់អាន

**ការជូនដំណឹងអំពីលទ្ធផល**

សូមអរគុណចំពោះការចូលរួមនៅក្នុងកម្មវិធីថ្នាក់ជាតិក្នុងការឆ្លុះពិនិត្យមើលជំងឺមហារីកពោះវៀន និងការបញ្ជូនត្រឡប់មកវិញនូវកញ្ចប់សម្ភារៈធ្វើតេស្តរបស់លោកអ្នក។

**លទ្ធផលធ្វើតេស្តរបស់លោកអ្នកបង្ហាញថាមានឈាមខ្លះត្រូវបានរកឃើញនៅក្នុងសំណាកគំរូមួយ ឬនៅក្នុងសំណាកគំរូទាំងពីរ។** នេះជាលទ្ធផលតេស្ត '**វិជ្ជមាន**'។ អាចមានហេតុផលមួយចំនួនដែលឈាមត្រូវបានគេរកឃើញ ហើយមានហេតុផលជាច្រើនគឺ**មិន**ទាក់ទងនឹងជំងឺមហារីកទេ។

**យ៉ាងណាក៏ដោយ វាជាការសំខាន់ដែលយើងត្រូវ ស្វែងរកមូលហេតុនៃការហូរឈាម ហើយខ្ញុំស្នើនិងជម្រុញ លោកអ្នកឲ្យធ្វើការណាត់ជួបជាមួយវេជ្ជបណ្ឌិតរបស់លោកអ្នក ឱ្យបានលឿនដែលអាចធ្វើទៅបាន ដែលប្រសើរបំផុតបើអាចធ្វើបាន គឺត្រូវជួបនៅក្នុងពីរសប្តាហ៍បន្ទាប់ ដើម្បីពិភាក្សាអំពីលទ្ធផលនេះ។ សូមយកលិខិតនេះទៅជាមួយលោកអ្នកផង។**

ប្រសិនបើលោកអ្នកបានតែងតាំងវេជ្ជបណ្ឌិត ឬឈ្មោះគ្លីនិកវេជ្ជសាស្ត្រ នៅក្នុងទម្រង់បែបបទដែលលោកអ្នកបានផ្ញើជាមួយនឹងសំណាកគំរូរបស់លោកអ្នក ពេលនោះលទ្ធផលធ្វើតេស្តរបស់លោកអ្នកក៏ត្រូវបានផ្ញើទៅឱ្យវេជ្ជបណ្ឌិតនោះហើយ។

វេជ្ជបណ្ឌិតរបស់លោកអ្នកអាចណែនាំឲ្យលោកអ្នក ជួបវេជ្ជបណ្ឌិតឯកទេសម្នាក់ ដើម្បីឱ្យមាននីតិវិធីមួយហៅថា ការឆ្លុះពិនិត្យមើលផ្នែកខាងក្នុងនៃពោះវៀនធំ។ នីតិវិធីនេះគឺជារបៀបដ៏ល្អបំផុតមួយក្នុងការស្វែងរកមូលហេតុដែលឈាមត្រូវបានរកឃើញនៅក្នុងចលនាពោះវៀនរបស់លោកអ្នក។ វេជ្ជបណ្ឌិតរបស់លោកអ្នក នឹងអាចផ្តល់ដល់លោកអ្នកនូវព័ត៌មានអំពីការឆ្លុះពិនិត្យមើលផ្នែកខាងក្នុងនៃពោះវៀនធំ អំពីអត្ថប្រយោជន៍ និងហានិភ័យរបស់វា ហើយនិងឆ្លើយសំណួរទាំងឡាយដែលលោកអ្នកអាចមាន។ លោកអ្នកក៏អាចឃើញព័ត៌មានអំពីការឆ្លុះពិនិត្យមើលផ្នែកខាងក្នុងនៃពោះវៀនធំនេះ នៅក្នុងកូនសៀវភៅផ្សព្វផ្សាយដែលភ្ជាប់មកជាមួយនេះផងដែរ។

.ប្រសិនបើលោកអ្នកមានសំណួរណាមួយអំពីកម្មវិធីនេះ សូមចូលមើល www.cancerscreening.gov.au ឬហៅទូរសព្ទទៅខ្សែទូរសព្ទព័ត៌មានកម្មវិធីតាមលេខ **1800 118 868** ក្នុងអំឡុងម៉ោងធ្វើការ។

ដោយសេចក្តីរាប់អាន

<Title> <Given Name> <Family Name>
គ្រូពេទ្យដែលផ្តល់ការអនុញ្ញាត